22100535

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A1 – STANDARD LEVEL – PAPER 1**
**KHMER A1 – NIVEAU MOYEN – ÉPREUVE 1**
**KHMER A1 – NIVEL MEDIO – PRUEBA 1**

Thursday 13 May 2010 (afternoon)
Jeudi 13 mai 2010 (après-midi)
Jueves 13 de mayo de 2010 (tarde)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a commentary on one passage only. It is not compulsory for you to respond directly to the guiding questions provided. However, you may use them if you wish.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire sur un seul des passages. Le commentaire ne doit pas nécessairement répondre aux questions d'orientation fournies. Vous pouvez toutefois les utiliser si vous le désirez.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario sobre un solo fragmento. No es obligatorio responder directamente a las preguntas que se ofrecen a modo de guía. Sin embargo, puede usarlas si lo desea.


© International Baccalaureate Organization 2010

*សូមអ្នកសរសេរអត្ថាធិប្បាយទៅលើអត្ថបទតែមួយ ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ*

*១*

[...] សូរកណ្ដឹងបានលាន់ឮ រ៉ឹងៗ... មីងភាពចេញមកបើកទ្វារ ស្រាប់តែមានពួកមិនស្គាល់មុខបីបួន នាក់គ្រាហ៏តារាចូលមកក្នុងស្អុយស្រាស្ទើរដកដង្ហើមមិនរួច ។

-«យី ! ក្មួយតារា... ទៅផឹកឯណាទាំងថ្ងៃ? ធុំស្រាណាស់ នេះដល់ថ្នាក់សែងតែម្ដង... ។»

កំលោះតារា ស្រវឹងរាងង៉ុលៗ ÷

-«មីង...មីង ! លោកពូ...នៅទេ?... »

-«ចាំស ! លោកប្រុសនៅ !... ចុះក្មួយ ព្រឹកមិញអត់ទៅបោះឆ្នោតទេឬ បានជាមកវិញ យ៉ាងនេះ?»

-«ហ៊ឺ ! មីង...មីងអ្ហា៎...ទៅពិបាកអី គេបោះបីថ្ងៃឯណោះ ! ថ្ងៃបង្អើយក៏បានដែរ !... អាសុខ អាហួរទៅវិញទៅ ! អញដល់ផ្ទះហើយ ម៉ូតូអញ ឯងជិះទៅណា !»

គេថាមនុស្សយើងដើរជាមួយចោរៗ ដើរជាមួយអ្នករៀនៗ ទោះបីមីងភាពឈរនៅទីនេះ គេចេញទៅពុំលាមួយម៉ាត់សោះឡើយ ។

-«តោះ ចូលទៅក្មួយ ! ប្រយ័ត្នដួល !... »

សិលាឃើញតារារកកល់នឹងដួល គេក៏ចេញមកជួយគ្រាហ៏ចូលបន្ទប់ ខ្លាចលោកវរៈសេនីយ៏ឃើញ ។

ពាក្យចាស់លោកបានពោលថា ចូលដប់មិនស្មើចេញមួយ យ៉ាងណាមិញមិត្តភក្តិដែលធ្លាប់ដណ្ដើមបាយគ្នាស៊ី រស់ក្រោមដំបូលវត្តជាមួយគ្នា គេហាក់ដូចជារសាប់រសល់ តាំងពីសិលាចេញទៅនៅជាមួយលោក វរៈសេនីយ៏មក ។ ពួកគេជានិស្សិតដែលធ្លាប់រស់នៅជុំគ្នាយ៉ាងសប្បាយរីករាយ ពេលនេះត្រូវបាត់សមាជិក ម្នាក់ ដែលធ្លាប់និយាយគ្នាលេង ធ្លាប់មានអនុស្សាវរីយ៏កម្សត់កម្រ ហេតុដែលធ្វើអោយគេសោកស្ដាយ គឺពេលរាត្រីច័ន្ទពេញវង់ ÷

យុវជនឈ្មោះសិដ្ឋនិយាយថា ÷

-«ហ៊ឺ ! សម្បត្តិ...តាំងពីសិលាទៅនៅជាមួយលោកវរៈសេនីយ៏មក ទីនេះហាក់ដូចជាស្ងាត់ ហើយដូចជាសោះកក្រោះទៀត !... »

សម្បត្តិអង្គុយក្រោមដើមអំពិលលើបង់ កាន់កូនវចនានុក្រម ហើយនិយាយតបមកកល្យាណមិត្ត ÷

-«ហ្នឹងហើយសិដ្ឋ ! កាលសិលានៅ... ថ្ងៃរនេះត្រូវពន្លឺច័ន្ទល្អផង ម្ល៉េះបែបមិនខ្វះសំណើច... រឿងខ្លីៗទេ !... »

កំលោះម្នាក់ទៀតឈ្មោះសុខាដើរចេញពីក្រោមកុដិមក តបថា ÷

-«អឺ ! សម្បត្តិនិយាយត្រូវ !... ព្រោះសិលាជាអ្នកទល់ដែនពូជសាមុត គេច្រៀងពិរោះណាស់ មិនដូចពួកយើងអ្នកខេត្តខាងកើតភ្នំពេញទេ !... »

-«នែ៎ ! សុខាអ៊ើយ... មិនត្រឹមតែខាងសំលេងទេ សូម្បីនិស្សិតចូលមហាវិទ្យាល័យទាំង២១ខេត្ត មានតែបាត់ដំបង បន្ទាយមានជ័យទេ ដែលចូលមកច្រើន !... ឯងមិនឃើញទេឬ កាលសិលានៅ មិត្តវាមក ច្រើនណាស់ដូចជាទ្រី ហិញ សាន អារដ្ឋ អាគុជ សុទ្ធា គង់... លើសពីនេះមានស្រីៗទៀត ! ឥឡូវតាំងពីសិលាទៅ ស្ងាត់អោយឈឹង មិនឃើញនរណាមកលេងទេ !... អ៊ូ ! ស្អែកនេះ នរណា ទៅផ្ទះខ្លះ ខ្លាចពេលប្រកាសលទ្ធផលឆ្នោត យើងបែកម៉ែពុក ! »

សម្បត្តិតបថា ÷

-«ឯងទៅចុះសិដ្ឋ ! ព្រោះកំពង់ធំនៅឆ្ងាយ ចំពោះគ្នា... កណ្ដាលរត់មួយភ្លែតដល់ហើយ !... »

-«ងាប់ហើយសិដ្ឋ ! ទៅភ័យអី?... ក្រែងអ៊ុនគាត់ការពារហើយ បើយើងរត់ចោលភ្នំពេញ អោយនរណានៅ?... ចុះអ៊ុន គាត់មានការងារអីធ្វើ?... »

ដោយមេឃត្រូវពពកបាំង រកកល់នឹងបង្ហូរព្រះភិរុណមកនោះ ក្រុមនិស្សិតនាំគ្នាចូលក្នុងអាស្រម វិញយ៉ាងរួតរះក្រៃលែង ។

ដកស្រង់ពីសៀវភៅ "រង់ចាំថ្ងៃនេះ" វគ្គទី ១១ "ប្រជាធិបតេយ្យ" និពន្ធដោយលោក យឹម សំណាង ឆ្នាំ ១៩៥៦

– តើអ្នកអាចនិយាយបានដូចម្ដេចខ្លះ អំពី គំនិតសំខាន់ ក្នុងរឿងខាងលើនេះ?

– សូមអ្នកធ្វើការអត្ថាធិប្បាយនូវ ការឆ្លើយតប ដែលរឿងនេះ អាចទាញចេញពីអ្នកស្ដាប់ ។

– តើអ្នកនិពន្ធចង់បញ្ជូនសារអ្វីខ្លះដល់ អ្នកអាន ក្នុងអត្ថបទកំនាព្យខាងលើ?

– ក្នុងអត្ថបទនេះ តើអ្នកយល់យ៉ាងណាចំពោះ អកប្បកិរិយារបស់អ្នកនិពន្ធទៅលើ "ការសេពគប់មិត្តភ័ក្តិ"?

២

អង្គរសម័យ    ស្មើរគ្រប់វិស័យ    ខ្មែរល្បីខ្ទរខ្ទារ
វិជ្ជាគំនិត    សម្បត្តិអរិយធម៌    រុងរឿងបវរ
    អាស៊ីអាគ្នេយ៍ ។
ទឹកដីខ្មែរធំ    រួបរួមសង្គម    រីករាយសាមគ្គី
កសាងជាតិខ្លួន    គ្រងស្ងួនភក្តិ    ការពារទឹកដី
    ពង្រឹងពូជខ្មែរ ។
គ្រប់កិច្ចការងារ    បុព្វខេមរា    គ្មានអួតពូកែ
គ្មានលើកខ្លួនឯង    នៅលើចង្កេរ    គ្មានអំនួតទេ
    ថ្នាក់មហាអស្ចារ្យ ។
ល្អនិងអាក្រក់    មិនបាច់កុហក    អួតប្រាប់លោកា
គេមានគំនិត    វិជ្ជាបញ្ញា    ឃើញប្រាកដការ
    ឥតមានសង្ស័យ ។
ខ្ញុំជាជាតិខ្មែរ    ពូជពង្សអ្នកស្រែ    តាំងពីតាយាយ
ស្រលាញ់គោរព    ជាតិខ្មែរគ្រប់កាយ    គ្មានមិត្តមើលងាយ
    មនុស្សលោកគ្រប់គ្នា ។
យុត្តិធម៌និងជាតិ    ស្រលាញ់មិនឃ្លាត    ប្តូរផ្តាច់ជីវ៉ា
បើយុត្តិធម៌ស្លាប់    ជាតិរស់យ៉ាងណា    រស់ក្នុងមាត់ខ្លា
    តើសង្ឃឹមអ្វី?

ដកស្រង់ពី កំនាព្យ "មើលផែនដីខ្មែរ" និពន្ធដោយ លោក ជួន ម៉េន បោះពុម្ព ឆ្នាំ ១៩៨០

– ក្នុងអត្ថបទកំនាព្យនេះ តើអ្នកយល់យ៉ាងណាចំពោះ អកប្បកិរិយារបស់អ្នកនិពន្ធទៅលើ "អំពើយុត្តិធម៌"?

– សូមអ្នកធ្វើការអត្ថាធិប្បាយ ទៅលើ ការប្រើភាសា ក្នុងអត្ថបទកំនាព្យខាងលើ ។

– តើអ្នកនិពន្ធចង់បញ្ជូនសារអ្វីខ្លះដល់ អ្នកអាន ក្នុងអត្ថបទកំនាព្យខាងលើ?

– តើអត្ថបទកំនាព្យខាងលើនេះ បានជះឥទ្ធិពលទៅលើអារម្មណ៍ និង អកប្បកិរិយា របស់អ្នក ចំពោះប្រទេសខ្មែរ យ៉ាងណាខ្លះ?